ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
លេខៈ...១៩៦...ភាដ.ណា...ប.ស្ថ

ថ្ងៃ សុក្រ ៩កើត ខែ ផល្គុន ឆ្នាំរកា នព្វស័ក ព.ស២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ២០១៨

# សេចក្តីជូនដំណឹង
## ស្តីពី
## អាហារូបករណ៍ KOICA ថ្នាក់អនុបណ្ឌិតសម្រាប់ឆ្នាំសិក្សា២០១៨

ក្រសួងបរិស្ថាន មានកិត្តិយសសូមជម្រាបជូនមន្ត្រីរាជការក្រសួងទាំងអស់ឱ្យបានជ្រាបថា ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) ប្រកាសផ្តល់អាហារូបករណ៍ថ្នាក់អនុបណ្ឌិតសម្រាប់ឆ្នាំសិក្សា ២០១៨ លើវិស័យចំនួនបីដែលមានដូចជាវិស័យបច្ចេកវិទ្យា វិស័យបរិស្ថាន និងវិស័យថាមពល ដល់មន្ត្រីក្នុងក្រសួង-ស្ថាប័នពាក់ព័ន្ធនានា ដើម្បីបន្តការសិក្សានៅសាធារណរដ្ឋកូរ៉េ។

ក្រសួងបរិស្ថាន សូមជូនដំណឹងដល់មន្ត្រីរាជការទាំងអស់ដែលមានចំណាប់អារម្មណ៍ចង់បន្តការសិក្សានៅសាធារណរដ្ឋកូរ៉េ សូមចូលទៅកាន់គេហទំព័រ www.koicacambodia.org/scholarship ឬ ទាក់ទងទៅកាន់ KOICA ដោយផ្ទាល់តាមរយៈប្រអប់សំបុត្រអេឡិចត្រូនិច koicascholar@gmail.com ឬ តាមរយៈលេខទូរស័ព្ទ 023 964 150, 023 964 151 ឬ 023 964 153 ។

ការទទួលពាក្យអាហារូបករណ៍នឹងបញ្ចប់ត្រឹមថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៨៕